ចំលងបញ្ជូន
នាយកដ្ឋានបុគ្គលិក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១...សរ.ណន..

ក្រសួងពាណិជ្ជកម្ម
ចូល លេខ: 8334
ថ្ងៃទី 15 ខែ 1 ឆ្នាំ២០០៩
បញ្ជូន

នាយកដ្ឋានបុគ្គលិក
ចូល លេខ: 563
27/01

# សារាចរណែនាំ
## ស្តីពី
## ការផ្អាកជាបណ្តោះអាសន្ននូវរាល់ការប្រឡងប្រជែងផ្ទៃក្នុងដើម្បីប្តូរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល

កន្លងមករាជរដ្ឋាភិបាលពិនិត្យឃើញថា ក្រសួង ស្ថាប័នមួយចំនួនបានស្នើសុំធ្វើការប្រឡងប្រជែងផ្ទៃក្នុង ដើម្បីប្តូរប្រភេទក្របខ័ណ្ឌរបស់មន្ត្រីរាជការ ដោយយកសញ្ញាប័ត្រតែមួយមុខគត់ធ្វើជាល័ក្ខខ័ណ្ឌសម្រាប់ការប្រឡងប្រជែង ដែលធ្វើឱ្យប៉ះពាល់ដល់ស្តង់ដារពីរាមីតនៃក្របខ័ណ្ឌនីមួយៗ និងនាំឱ្យមានផលវិបាកដល់ការគ្រប់គ្រងក្របខ័ណ្ឌមុខងារសាធារណៈ ។

ឈរលើស្មារតីនេះ ដើម្បីធានាបាននូវប្រសិទ្ធភាព និងនិរន្តរភាពនៃការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័ន ដូចខាងក្រោម :

១-ផ្អាកជាបណ្តោះអាសន្នរាល់ការប្រឡងប្រជែងផ្ទៃក្នុងដើម្បីប្តូរក្របខ័ណ្ឌ ដោយយកសញ្ញាប័ត្រតែមួយគត់ធ្វើជាល័ក្ខខ័ណ្ឌ ។

២-ប្រគល់ភារកិច្ចឱ្យអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល សហការជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងគ្រប់ក្រសួង ស្ថាប័ន ដើម្បីកំណត់គោលការណ៍អនុវត្តដូចខាងក្រោម :

-កំណត់ឱ្យបានច្បាស់លាស់ពីស្តង់ដារពីរ៉ាមីត តាមប្រភេទនៃក្របខ័ណ្ឌនីមួយៗ

-កំណត់ចំនួនមុខតំណែងទំនេរនៃក្របខ័ណ្ឌនីមួយៗប្រចាំឆ្នាំសម្រាប់ការប្រឡងប្រជែងប្តូរក្របខ័ណ្ឌ

-រកដំណោះស្រាយ ដើម្បីធានាបាននូវភាពត្រឹមត្រូវនៃសញ្ញាប័ត្រសម្រាប់ការប្រឡងប្រជែងប្តូរក្របខ័ណ្ឌ

-រកដំណោះស្រាយចំពោះមន្ត្រីក្រមការ ដែលចេញពីសាលាភូមិន្ទរដ្ឋបាល ហើយមានសញ្ញាប័ត្រចាប់ពីបរិញ្ញាប័ត្រឡើងទៅ ដើម្បីប្រឡងប្រជែងប្តូរក្របខ័ណ្ឌ

-រកមធ្យោបាយផ្តល់លទ្ធភាពដល់មន្ត្រីសកម្មការងារ ដែលពុំមានពេលវេលាគ្រប់គ្រាន់ទៅរៀនយកសញ្ញាប័ត្រខ្ពស់ ឱ្យបានចូលរួមប្រឡងប្រជែងដើម្បីប្តូរក្របខ័ណ្ឌ

គីម_ស៊ីថន

-កំណត់មុខជំនាញវិជ្ជាជីវៈរបស់មន្ត្រីរដ្ឋបាលឱ្យបានច្បាស់លាស់

-រៀបចំយន្តការ នីតិវិធី និងបែបបទសម្រាប់ការប្រឡងប្រជែងផ្ទៃក្នុងដើម្បីប្តូរក្របខ័ណ្ឌឱ្យមានស្តង់ដារគុណភាពខ្ពស់

-ចំពោះក្របខ័ណ្ឌដែលផ្អែកលើជំនាញវិជ្ជាជីវៈច្បាស់លាស់( គ្រូពេទ្យ គ្រូបង្រៀន អ្នកបច្ចេកទេស) ការប្តូរក្របខ័ណ្ឌអាចប្រព្រឹត្តទៅបានលុះត្រាតែបានទៅបន្តការសិក្សាស្របតាមជំនាញវិជ្ជាជីវៈរបស់ខ្លួន ហើយបានទទួលសញ្ញាប័ត្រខ្ពស់ជាង ។

៣-ក្រោយពីកសាងបានគោលការណ៍សម្រាប់អនុវត្តខាងលើនេះរួចហើយ ត្រូវរៀបចំបែបបទស្នើសុំការសម្រេចពីរាជរដ្ឋាភិបាលដើម្បីដាក់ឱ្យអនុវត្ត ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ៣ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**<u>កន្លែងទទួល</u> :**

-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ